# យុទ្ធសាស្ត្រប្រតិបត្តិការសំរាប់ភាពជាដៃគូ ផ្លូវហោះហើរអូស្ត្រាលី-អាស៊ីខាងកើត៖២០០៧-២០១១



ឯកសារនេះដកស្រង់ចេញពីអត្ថបទភាពជាដៃគូដោយផ្ទាល់ និងផ្តល់ជាយន្តការសំរាប់ណែនាំការប្រតិបត្តិ នៃភាពជាដៃគូ សំរាប់ផ្លូវហោះហើរអូស្ត្រាលី-អាស៊ីខាងកើត ។

ឯកសារនេះបង្កើតឡើងចេញពីសេចក្តីព្រាងដែលរៀបចំដោយក្រុមការងារភាពជាដៃគូ ដោយអនុលោមតាមការពិភាក្សា នៅក្នុងកិច្ចប្រជុំភាគីដៃគូ នៅទីក្រុងបូហ្គ័រ ប្រទេសឥណ្ឌូណេស៊ី ។

## ១. សេចក្តីផ្តើម

ជារៀងរាល់ឆ្នាំ សត្វស្លាបទឹកច្រើនជាង៥០លាន ធ្វើទេសន្តរប្រវេសន៍ នៅទូទាំងតំបន់អាស៊ីខាងកើត, អាស៊ីអាគ្នេយ៍ និងអូស្ត្រាលី ។ កំឡុងពេលទេសន្តរប្រវេសន៍ សត្វស្លាបទឹកទាំងនោះពឹងផ្អែកលើសង្វាក់ផលិតផលតំបន់ដីសើមដ៏ខ្ពស់ ដើម្បីសំរាក និងរកចំណីបង្កើនថមពលសំរាប់ធ្វើដំណើរនៅដំណាក់កាលបន្ទាប់ ។ ដូច្នេះ សហប្រតិបត្តិការអន្តរជាតិ នៅទូទាំងតំបន់ដែលសត្វធ្វើទេសន្តរប្រវេសន៍ គឺសំខាន់ណាស់ ដើម្បីអភិរក្សនិងការពារសត្វស្លាបទឹកទេសន្តរប្រវេសន៍និងទីជម្រករបស់វា ។

តំបន់ដែលសត្វស្លាបទាំងនោះធ្វើទេសន្តរប្រវេសន៍ ហៅថា ផ្លូវហោះហើរអូស្ត្រាលី-អាស៊ីខាងកើត (ផ្លូវហោះហើរ)។ ផ្លូវហោះហើរគ្របដណ្តប់លើប្រទេសចំនួន២២ ដែលលាតសន្ធឹងពីតំបន់ខាងកើតប្រទេសរ៉ូស៊ី និងអាឡាស្កា តំបន់ខាងត្បូងឆ្ពោះទៅអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ និងឆ្ពោះទៅអូស្ត្រាលីនិងប្រទេសញ៉ូវហ្ស៊ីឡង់ (រូបទី ១)។

នៅឆ្នាំ២០០២, ក្នុងកិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព (WSSD) នៅជូហ៊ាននេស្បឺក (Johanneshurg) រដ្ឋាភិបាលជប៉ុននិងអូស្ត្រាលី រួមជាមួយអង្គការដីសើមអន្តរជាតិ បានលើកសំណើភាពជាដៃគូប្រភេទទី២ សំរាប់ការអភិរក្ស និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិ សំរាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍ នៅអាស៊ីខាងកើត អាស៊ីអគ្នេយ៍ និងអូស្ត្រាលី ។

ភាពជាដៃគូបង្កើតឡើងតាមរយៈសមិទ្ធិកម្ម របស់គណៈកម្មាធិការអភិរក្សសត្វស្លាបទឹកទេសន្តរប្រវេសន៍នៅអាស៊ីប៉ាស៊ីហ្វិក យុទ្ធសាស្ត្រអភិរក្សសត្វស្លាបទឹកទេសន្តរប្រវេសន៍អាស៊ីប៉ាស៊ីហ្វិក និងផែនការសកម្មភាពរបស់គេសំរាប់សត្វស្លាបពួកទាទឹក ពួកក្រៀល និងពួកសត្វស្លាបតំបន់ឆ្នេរ ។ ក្នុងកំឡុងពេល១៩៩៦-២០០៦ ផែនការសកម្មភាពនិងយុទ្ធសាស្ត្របានពង្រឹងសហប្រតិបត្តិការអន្តរជាតិ ការសម្របសម្រួល និងសកម្មភាព ដើម្បីអភិរក្សនិងការពារទីជម្រកដែលមានសារៈសំខាន់ជាអន្តរជាតិ សំរាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍។

សមិទ្ធិកម្មនៃយុទ្ធសាស្ត្រនិងផែនការសកម្មភាពនេះរួមមាន៖ ការកំណត់តំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិសំរាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍ជាង៧០០កន្លែង នៅក្នុងផ្លូវហោះហើរ និងការបង្កើតបណ្តាញតំបន់សំរាប់សត្វស្លាបពួកទាទឹក ពួកក្រៀល និងពួកសត្វស្លាបតំបន់ឆ្នេរ ។ លទ្ធផលដែលបានពីការអនុវត្តសកម្មភាពរួមមាន៖ ការបង្កើនចំណេះដឹងស្តីពីសត្វស្លាបទឹកទេសន្តរប្រវេសន៍ ការផ្សព្វផ្សាយស្តីពីសារៈសំខាន់សត្វស្លាបទឹក និងពង្រឹងសមត្ថភាពរបស់អ្នកគ្រប់គ្រង ដើម្បីថែរក្សាតំបន់ដែលមានសារៈសំខាន់សំរាប់សត្វស្លាបទឹក នៅក្នុងផ្លូវហោះហើរ ។ សកម្មភាពទាំងនេះបានធ្វើឲ្យប្រសើរឡើងការគ្រប់គ្រងបណ្តាញតំបន់ ។

ទោះបីជា មានការខិតខំប្រឹងប្រែងទាំងនេះយ៉ាងណាក៏ដោយ សត្វស្លាបទឹក ទីជម្រកទឹកសាបនិងតំបន់ឆ្នេររបស់វាស្ថិតនៅក្រោមសម្ពាធដែលចេះតែកើនឡើង នៃកំណើនប្រជាពលរដ្ឋយ៉ាងឆាប់រហ័សនិងការអភិវឌ្ឍសេដ្ឋកិច្ច

ជាពិសេស នៅតំបន់អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ ។ សម្ពាធទាំងនោះប៉ះពាល់ដល់សត្វស្លាបទឹក ដែលចំណាយពេលក្នុងរដូវមិនពងកូននៅក្នុងប្រទេសទាំងនោះ ក៏ដូចជាសត្វស្លាបទឹកដែលប្រើប្រាស់ផ្នែកកណ្តាលនៃផ្លូវហោះហើរ ក្នុងកំឡុងពេលនៃទេសន្តរប្រវេសន៍។ ភាពជាដៃគូនេះ ទទួលស្គាល់សារៈសំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ចសំរាប់សហគមន៍ដែលរួមចំណែកតំបន់ដែលមានសារៈសំខាន់នេះជាមួយសត្វស្លាបទឹក ដោយធានាភាពដែលអាចរកបាន និងគុណភាពនៃទីជម្រកដែលត្រូវការ ដើម្បីថែរក្សាចំនួននៃសត្វស្លាបទឹកទេសន្តរប្រវេសន៍ទាំងនោះ ។

ភាពជាដៃគូទទួលស្គាល់ថា ការបង្កើត និងធ្វើឲ្យប្រសើរឡើងបណ្តាញតំបន់ផ្លូវហោះហើរសំរាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍, ការបង្កើតសមត្ថភាពពាក់ព័ន្ធនៅកម្រិតមូលដ្ឋាន ដើម្បីធានាការផ្តល់សេវកម្មអេកូឡូស៊ីប្រកបដោយនិរន្តរភាព នឹងពង្រឹងស្ថានភាពអភិរក្សសត្វស្លាបទឹកទេសន្តរប្រវេសន៍ទាំងនេះ ។ ភាពជាដៃគូទទួលស្គាល់ផងដែរថា វិធីសាស្រ្តផ្លូវហោះហើរដ៏ទូលាយចំពោះការអភិរក្សសត្វស្លាបទឹកអន្តរប្រវេសន៍គឺជាវិធីដែលមានប្រសិទ្ធភាពបំផុត ដើម្បីពង្រឹងស្ថានភាពអភិរក្ស។

ការងាររបស់ភាពជាដៃគូ ផ្តោតលើគ្រប់ចំនួននៃសត្វស្លាបទឹកទេសន្តរប្រវេសន៍ទាំងអស់នៅក្នុងផ្លូវហោះហើរអូស្រ្តាលី- អាស៊ីខាងកើត (តារាង ១)។

**រូបទី ១៖ ផែនទីផ្លូវហោះហើរ អូស្រ្តាលី- អាស៊ីខាងកើត**



**តារាង ១៖ ចំណាត់ថ្នាក់ក្រុម នៃសត្វស្លាបទឹកទេសន្តរប្រវេសន៍នៅក្នុងផ្លូវហោះហើរអូស្ត្រាលី- អាស៊ីខាងកើត**

| អំបូរ | ឈ្មោះទូទៅជាភាសាអង់គ្លេស |
|---|---|
| Gaviidae | Divers/Loons |
| Podicipedidae | Grebes |
| Phalacrocoracidae | Cormorants |
| Procellarridae | Shearwaters |
| Oceanitidae | Storm Petrels |
| Pelecanidae | Pelicans |
| Ardeidae | Herons, Egrets and Bitterns |
| Ciconiidae | Storks |
| Threskiornithidae | Ibises and Spoonbills |
| Anatidae | Swans, Geese and Ducks |
| Gruidae | Cranes |
| Rallidae | Rails, Gallinules and Coots |
| Heliornithidae | Finfoots |
| Jacanidae | Jacanas |
| Haematopodidae | Oystercatcher |
| Recurvirostridae | Stilts and Avocet |
| Glareolidae | Pratincoles |
| Charadriidae | Plovers |
| Scolopacidae | Sandpipers |
| Laridae | Gulls, Terns and Skimmers |
| Stercorariidae | Auks |
| Alcidae | Skuas |

## ២.លទ្ធផលដែលជាយុទ្ធសាស្ត្រ

### ២.១ គោលដៅ និងគោលបំណង

ភាគីដៃគូផ្តួចផ្តើមបានព្រមព្រៀងលើគោលដៅ និងគោលបំណងចំនួន ៥ សំរាប់ភាពជាដៃគូដូចខាងក្រោម ៖

**គោលដៅ៖** សត្វស្លាបទឹកទេសន្តរប្រវេសន៍ និងទីជម្រករបស់វា នៅក្នុងផ្លូវហោះហើរអូស្ត្រាលី-អាស៊ីខាងកើតត្រូវទទួលស្គាល់ និងអភិរក្ស សំរាប់ផលប្រយោជន៍ប្រជាពលរដ្ឋ និងជីវៈចម្រុះ ។

គោលបំណង៖

១. អភិវឌ្ឍបណ្តាញតំបន់ផ្លូវហោះហើរ ដែលមានសារៈសំខាន់ជាអន្តរជាតិ សំរាប់ការអភិរក្សសត្វស្លាបទឹកទេសន្តរប្រវេសន៍ និងបង្កើនសមិទ្ធិកម្ម នៃបណ្តាញ APMWCS

២. ពង្រឹងការទំនាក់ទំនង ការអប់រំ និងការផ្សព្វផ្សាយជាសាធារណៈអំពីតម្លៃសត្វស្លាបទឹកអន្តរប្រវេសន៍ និងទីជម្រករបស់វា

៣. ពង្រឹងសកម្មភាពឃ្លាំមើល និងសិក្សាស្រាវជ្រាវ, បង្កើនចំណេះដឹង, និងជំរុញការផ្លាស់ប្តូរពត៌មានអំពីសត្វស្លាបទឹកទេសន្តរប្រវេសន៍ និងទីជម្រករបស់វា

៤. បង្កើនសមត្ថភាពគ្រប់គ្រងសត្វស្លាបទឹក និងទីជម្រកដល់អ្នកគ្រប់គ្រងធនធានធម្មជាតិ អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកពាក់ព័ន្ធនៅមូលដ្ឋាន

៥. បង្កើតកម្មវិធីឲ្យទូលំទូលាយសំរាប់ផ្លូវហោះហើរ ជាពិសេស សំរាប់ប្រភេទ និងទីជម្រកអាទិភាព ដើម្បីពង្រឹងស្ថានភាពអភិរក្សនៃសត្វស្លាបទឹកទេសន្តរប្រវេសន៍ ។

ក្រុមការងារភាពជាដៃគូ ដែលត្រូវបានបង្កើតនៅសម័យប្រជុំលើកទីមួយ នៃភាគីដៃគូដែលមានសក្តានុពល បានកំណត់លទ្ធផលសំខាន់ៗចំនួន១៣ ដែលត្រូវធ្វើឲ្យបានសម្រេច តាមរយៈភាពជាដៃគូនេះ នៅចុងឆ្នាំ២០១១។

## ៣.ការបង្កើតនិងការប្រតិបត្តិភាពជាដៃគូ

### ៣.១ សមាជិកភាពនៃភាពជាដៃគូ

ភាពជាដៃគូមានគោលបំណង ដើម្បីពង្រីកសមាជិកភាពឲ្យទូលំទូលាយ ដោយរួមបញ្ចូលទាំងរដ្ឋាភិបាលជាតិ អង្គការមិនមែនរដ្ឋាភិបាល អន្តរជាតិ អង្គការអន្តររដ្ឋាភិបាល ផ្នែកជំនួញអន្តរជាតិ ។ ភាគីដៃគូលើកទឹកចិត្ត រដ្ឋាភិបាលជាតិ និងអង្គការផ្សេងទៀតដែលពាក់ព័ន្ធនឹងផ្លូវហោះហើរ ក្នុងការអភិរក្សសត្វស្លាបទឹកទេសន្តរប្រវេសន៍ និងការប្រើប្រាស់ប្រកបដោយចីរភាពនៃទីជម្រករបស់វា ឲ្យចូលរួមក្នុងភាពជាដៃគូនេះ ។

ភាពជាដៃគូ គឺជាការរៀបចំចាត់ចែងសហប្រតិបត្តិការមួយ និងមិនមែនជាអង្គភាពដែលបង្កើតឡើងដោយច្បាប់ឡើយ ។ ភាគីដៃគូចូលជាសមជិកភាពជាដៃគូ តាមរយៈការចុះហត្ថលេខាលើច្បាប់ចម្លង នៃអត្ថបទភាពជាដៃគូមួយ ។

### ៣.២ ថវិកាភាពជាដៃគូ

ភាគីដៃគូ ត្រូវលើកទឹកចិត្តឲ្យផ្តល់ធនធាន ដើម្បីគាំទ្រកម្មវិធីការងារ និងកិច្ចការរដ្ឋបាលនៃភាពជាដៃគូ ។ កិច្ចប្រជុំនៃភាគីដៃគូនឹងប៉ាន់ប្រមាណសេចក្តីត្រូវការ និងជម្រើសសំរាប់បង្កើតប្រភពថវិកា ៖

ក) វាយតម្លៃភាគីដៃគូ ដើម្បីអនុវត្តសកម្មភាព ដែលស្ថិតនៅក្រោមភាពជាដៃគូនេះ និង

ខ) ការចំណាយដែលត្រូវការសំរាប់ប្រតិបត្តិការលេខាធិការដ្ឋាន និងក្រុមប្រឹក្សាដែលបានបង្កើត នៅក្រោមភាពជាដៃគូនេះ ។

ដោយសារភាពជាដៃគូនេះគឺមិនមែនជាអង្គភាពដែលកើតឡើងដោយច្បាប់មូលនិធិនឹងត្រូវការផ្តល់ដោយផ្ទាល់តាមរយៈភាគីដៃគូ ។

## ៣.៣ ក្រុមការងារ

ការអភិវឌ្ឍនៃសកម្មភាព ដើម្បីរៀបរាប់អំពីលទ្ធផលដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ នឹងត្រូវការការសម្របសម្រួលកំណត់ខ្ពស់បំផុត រវាងភាគីដៃគូ ។ កម្មវិធីការងារប្រចាំឆ្នាំនឹងត្រូវរៀបចំនៅក្នុងកិច្ចប្រជុំនីមួយៗ នៃភាគីដៃគូ និងនឹងមានសកម្មភាពដែលបានលើកផែនការ ដោយភាគីដៃគូ ។

## ៣.៤ ការណែនាំសំរាប់ការអភិវឌ្ឍនៃសកម្មភាពគម្រោង

ភាពជាដៃគូបានរៀបចំការណែនាំ ដើម្បីជួយភាគីដៃគូ ក្នុងការអភិវឌ្ឍគម្រោងជាយុទ្ធសាស្ត្រ ដើម្បីកំណត់លទ្ធផល ២០១១ ដែលបានកំណត់នៅក្នុងឯកសារនេះ ។

គោលបំណង១៖ អភិវឌ្ឍបណ្តាញផ្លូវហោះហើរ នៃតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិសំរាប់ការអភិរក្សសត្វស្លាបទឹកទេសន្តរប្រវេសន៍ បង្កើនសមិទ្ធិផលនៃបណ្តាញ APMWCS

**លទ្ធផល ១៖ បណ្តាញតំបន់ផ្លូវហោះហើរបានបង្កើតឡើងដោយរួមបញ្ចូលយ៉ាងហោចណាស់២០០តំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិ សំរាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍ ។**

១.១ ភាពជាដៃគូ ត្រូវជំរុញគ្រប់ប្រទេសទាំងអស់ នៅក្នុងផ្លូវហោះហើរ ដែលមានតំបន់សំខាន់ជាអន្តរជាតិ សំរាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍ ។

១.២ ដោយស្វែងរកការកំណត់ជាបណ្តាញតំបន់ផ្លូវហោះហើរ អាទិភាពគឺត្រូវផ្តល់ជូនប្រទេសដែលមានដៃគូរដ្ឋាភិបាលជាតិមួយ និងមិនទាន់កំណត់តំបន់ រឺ មានភាគរយទាប (<១០%) នៃតំបន់សំខាន់ជាអន្តរជាតិរបស់គេ ដាក់បញ្ចូលនៅក្នុងបណ្តាញតំបន់ផ្លូវហោះហើរ ។

១.៣ ចំនួនដែលពាក់ព័ន្ធ នៃតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិ នៅក្នុងប្រទេសមួយត្រូវប្រើប្រាស់ ដើម្បីណែនាំជាអាទិភាពនៅកម្រិតផ្លូវហោះហើរ ។

១.៤ ភាពជាដៃគូជាតិកំណត់អាទិភាពសំរាប់ការបញ្ចូលតំបន់នៅក្នុងប្រទេសរបស់ពួកគេ ។

**លទ្ធផល ២៖ សកម្មភាពគ្រប់គ្រងនៅតំបន់ដែលជាលទ្ធផលការបាត់បង់ជីវចម្រុះពាក់កណ្តាល រឺ ការកើនឡើងចំពោះស្ថានភាពអភិរក្សនៃប្រភេទដែលគួរព្រួយបារម្មណ៍**

**លទ្ធផល ៣៖ បណ្តាញតំបន់ផ្លូវហោះហើរ កំពុងផ្តោតយកចិត្តទុកដាក់លើសមាហរណកម្មនៃការអភិរក្ស ជីវចម្រុះតំបន់ដីសើម និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលផ្តល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋាន ។**

៣.១ បង្កើត និងអនុវត្តផែនការគ្រប់គ្រងបណ្តាញតំបន់ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធកម្រិតជាតិ និងកម្រិតមូលដ្ឋានសំខាន់ៗ ដែលទទួលស្គាល់តម្រូវការអេកូឡូស៊ីសំរាប់សត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍ និងតម្រូវការសេដ្ឋកិច្ចសង្គមរបស់សហគមន៍ដែលពឹងអាស្រ័យផល ។

៣.២ អ្នកគ្រប់គ្រងតំបន់ ដៃគូជាតិ និងសហគមន៍មូលដ្ឋាន ត្រូវលើកទឹកចិត្តឲ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តស្តីពីដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ដែលនឹងប៉ះពាល់ដល់បណ្តាញតំបន់

៣.៣ កិច្ចសហប្រតិបត្តិការត្រូវបង្កើតជាមួយនឹងគម្រោងអន្តរជាតិដទៃទៀត ដែលទាក់ទងនឹងការគ្រប់គ្រងទីជម្រកសត្វស្លាបទឹកទេសន្តរប្រវេសន៍ ។

៣.៤ គម្រោងគំរូត្រូវបង្កើតឡើង ដោយចូលរួមយ៉ាងពេញទំហឹងរបស់ភាពដៃគូជាតិ និងតំបន់ ។

៣.៥ គម្រោងគំរូនៅកម្រិតបណ្តាញតំបន់កំណត់ដំណើរការគម្រាមកំហែងសំខាន់ៗ តម្រូវការសេដ្ឋកិច្ចសង្គម និងផ្តល់វិភាគទានដើម្បីធ្វើសមាហរណកម្ម នៃការអភិរក្សជីវចម្រុះតំបន់ដីសើម និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលផ្តល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋាន ។

៣.៦ គោលការណ៍ណែនាំគ្រប់គ្រងតំបន់ត្រូវបង្កើតឡើង ដោយភាគីដៃគូផ្លូវហោះហើរសំរាប់បណ្តាញតំបន់ផ្លូវហោះហើរ ដែលផ្អែកលើគោលការណ៍ណែនាំដែលមានស្រាប់ (ឧទាហរណ៍ៈ គោលការណ៍ណែនាំរាមសារសំរាប់គ្រប់គ្រងតំបន់ដីសើម) ។

**លទ្ធផល ៤: តម្លៃសេដ្ឋកិច្ច សង្គម និងអេកូឡូស៊ីនៃតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិសំរាប់សត្វស្លាបទឹកត្រូវបានទទួលស្គាល់ក្នុងដំណើរការអភិវឌ្ឍ និងវាយតម្លៃហេតុប៉ះពាល់**

៤.១ ការបង្កើនចំណេះដឹងអំពីសារៈសំខាន់នៃតម្លៃសេដ្ឋកិច្ច សង្គម និងអេកូឡូស៊ីនៃតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិសំរាប់សត្វស្លាបទឹកត្រូវទទួលស្គាល់ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់ និងការអភិវឌ្ឍ (ដូចជា តាមរយៈការបង្កើនការអនុវត្តគោលការណ៍ណែនាំរាមសារ និងគោលការណ៍ណែនាំវាយតម្លៃហេតុប៉ះពាល់បរិស្ថាន CBD)។

៤.២ ករណីសិក្សាអំពីដំណើរការវាយតម្លៃហេតុប៉ះពាល់ និងការអភិវឌ្ឍ ដែលប៉ះពាល់តំបន់ និងទីជម្រាលរបស់វា គឺអាចរកបាន ។

៤.៣ ភាពជាដៃគូជាតិ កំណត់អាទិភាពសំរាប់សកម្មភាពគម្រោងនៅក្នុងប្រទេសរបស់ពួកគេ ។

គោលបំណង២ : ពង្រឹងទំនាក់ទំនង ការអប់រំ និងការផ្សព្វផ្សាយជាសាធារណៈស្តីពីតម្លៃសត្វស្លាបទឹកអន្តរប្រវេសន៍ និងទីជម្រករបស់វា ។

**លទ្ធផល ៥: មានការយល់ដឹង និងទទួលស្គាល់កម្រិតខ្ពស់នៃតម្លៃសេដ្ឋកិច្ច សង្គម និងអេកូឡូស៊ីនៃសត្វស្លាបទឹកទេសន្តរប្រវេសន៍ និងបណ្តាញតំបន់**

៥.១ កម្មវិធីអប់រំ និងផ្សព្វផ្សាយសហគមន៍ទូលំទូលាយស្តីពីផ្លូវហោះហើរ ត្រូវបង្កើតឡើង និងផ្តល់ការណែនាំបន្តសំរាប់សកម្មភាពទំនាក់ទំនងនិងផ្សព្វផ្សាយអំពីភាពជាដៃគូផ្លូវហោះហើរ ។

៥.២ ការពិនិត្យឡើងវិញ នៃការទំនាក់ទំនង និងធនធានផ្សព្វផ្សាយត្រូវអនុវត្ត

៥.៣ ភាពជាដៃគូជាតិត្រូវគេលើកទឹកចិត្តឲ្យរៀបចំផែនការ CEPA ដែលបំពេញឲ្យផែនការ CEPA របស់ភាពជាដៃគូផ្លូវហោះហើរ។

៥.៤ សកម្មភាពទំនាក់ទំនង និងផ្សព្វផ្សាយជាច្រើន ត្រូវអនុវត្ត ដែលស្របគ្នានឹងផែនការទំនាក់ទំនង និងផ្សព្វផ្សាយជាសាធារណៈ ។

**លទ្ធផល ៦: មានការទទួលស្គាល់នូវសកម្មភាពនិងសម្មិទ្ធិផលនៃភាពជាដៃគូផ្លូវហោះហើរក្នុងកម្រិតយ៉ាងទូលំទូលាយ**

៦.១ សកម្មភាពជម្រុញភាពជាដៃគូត្រូវអនុវត្តស្របតាមផែនការទំនាក់ទំនង និងផ្សព្វផ្សាយជាសាធារណៈ ។

គោលបំណង៣ : **ពង្រឹងសកម្មភាពឃ្លាំមើល និងស្រាវជ្រាវផ្លូវហោះហើរ, បង្កើនចំណេះដឹង និងជម្រុញការផ្លាស់ប្តូរពត៌មានស្តីពីសត្វស្លាបទឹក និងទីជម្រករបស់វា ។**

**លទ្ធផល៧: ព័ត៌មានដែលមានលក្ខណៈវិទ្យាសាស្ត្រស្តីពីស្ថានភាពផ្លូវហោះហើរ និងនិន្នាការ នៃចំនួនសត្វស្លាបទឹក និងទីជម្រក គឺអាចរកបាន**

៧.១ កម្មវិធីតាមដានផ្លូវហោះហើរសត្វស្លាបទឹក ដែលផ្សារភ្ជាប់នឹងកម្មវិធីជាតិ និងអន្តរជាតិដែលមានស្រាប់ ត្រូវបង្កើតឡើង ។

៧.២ កម្មវិធីតាមដានទីជម្រកសត្វស្លាបទឹកក្នុងផ្លូវហោះហើរ ដែលផ្សារភ្ជាប់នឹងកម្មវិធីជាតិ និងអន្តរជាតិដែលមានស្រាប់ ត្រូវបង្កើតឡើងនៅទីកន្លែងនិងតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិ ។

៧.៣ ព័ត៌មានទាន់ហេតុការណ៍ គឺអាចរកបានស្តីពីស្ថានភាព និងការគម្រាមកំហែងចំពោះតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិ និងជាពិសេស ចំពោះបណ្តាញតំបន់ ។

៧.៤ ភាគីដៃគូធ្វើសហការលើសកម្មភាពតាមដានសត្វស្លាបទឹក (រួមទាំងកត្តាជីវៈ) និងពង្រឹងសកម្មភាព ប្រមូលទិន្នន័យដែលមានលក្ខណៈវិទ្យាសាស្រ្ត និងការវិភាគនៃស្ថានភាព និងនិន្នាការនៃចំនួនសត្វស្លាបទឹក ។

៧.៥ សកម្មភាពតាមដានរួមបញ្ចូលសមាសភាពនៃការអភិវឌ្ឍសមត្ថភាពសមស្រប ដើម្បីបង្កើនជំនាញតាមដានសត្វស្លាបទឹក ។

**លទ្ធផល៨: ព័ត៌មានស្តីពីតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិសំរាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍នៅគ្រប់ប្រទេសនៃផ្លូវហោះហើរ គឺអាចរកបាន**

៨.១ ការពិនិត្យឡើងវិញនៃព័ត៌មានស្តីពីតបន់ដែលមានសារៈសំខាន់ជាអន្តរជាតិសំរាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍ នៅក្នុងផ្លូវហោះហើរ គឺត្រូវរៀបចំនិងបោះពុម្ពផ្សព្វផ្សាយ

៨.២ ខ្វះចន្លោះចំណេះដឹងស្តីពីតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិ ត្រូវធ្វើការផ្ទៀងផ្ទាត់តាមរយៈសកម្មភាពចុះអង្កេត ។

៨.៣ ទិន្នន័យស្តីពីតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិ គឺអាចរកបាន និងចែករំលែករវាងភាគីដៃគូ

៨.៤ អាទិភាព គឺការអនុវត្តនៃការចុះអង្កេតនៅក្នុងតំបន់ដែលការវាយតម្លៃនៃការខ្វះចន្លោះចំណេះដឹងបាននិងកំពុងបង្ហាញទិន្នន័យអង្កេតនៅមានកម្រិត ប៉ុន្តែទីជម្រកដែលមានសក្តានុពលសំខាន់ណាស់

៨.៥ សកម្មភាពអង្កេតរួមបញ្ចូលជាមួយសមាសភាពអភិវឌ្ឍសមត្ថភាព ដើម្បីបង្កើនជំនាញអង្កេតសត្វស្លាបទឹក។

**លទ្ធផល៩: ការគម្រាមកំហែងតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិសំរាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍ត្រូវបានវាយតម្លៃ និងផ្តល់អនុសាសន៍សំរាប់បង្កើតវិធានការគ្រប់គ្រងសមស្រប**

៩.១ គោលការណ៍ណែនាំ ស្តីពីការវាយតម្លៃហេតុប៉ះពាល់ និងការគម្រាមកំហែងត្រូវបង្កើតឡើង ។

៩.២ ការពិនិត្យឡើងវិញនៃការគម្រាមកំហែង និងតម្រូវការគ្រប់គ្រងនៅកម្រិតបណ្តាញតំបន់ និងតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ ត្រូវអនុវត្ត ។

៩.៣ បច្ចេកទេសលប់បំបាត់ និងគោលការណ៍ណែនាំសំរាប់លប់បំបាត់ហេតុប៉ះពាល់ត្រូវបង្កើតឡើង។

៩.៤ សកម្មភាពរួមបញ្ចូលសមាសភាពអភិវឌ្ឍសមត្ថភាពសមស្រប ដើម្បីបង្កើនជំនាញក្នុងការវាយតម្លៃការគម្រាមកំហែង និងផែនការឆ្លើយតប ។

៩.៥ ការចូលរួមរបស់អ្នកឯកទេស និងអ្នកជំនាញក្នុងមូលដ្ឋាន ។

**លទ្ធផល១០: ចំណេះដឹងស្តីពីអេកូឡូស៊ី និងយុទ្ធសាស្ត្រទេសន្តរប្រវេសន៍របស់សត្វស្លាបទឹក គឺត្រូវពង្រឹងដើម្បីគាំទ្រវិធានការណ៍អភិរក្ស ។**

១០.១ គម្រោងទេសន្តរប្រវេសន៍សហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តចំពោះប្រភេទអាទិភាព ។

១០.២ ក្បួនដៅសម្គាល់សត្វស្លាបទឹកទេសន្តរប្រវេសន៍ត្រូវបង្កើតសំរាប់សត្វស្លាបទឹកអន្តរប្រវេសន៍ភាគច្រើន ។

១០.៣ មានការសម្របសម្រួលកម្រិតខ្ពស់រវាងការពាក់កងសត្វស្លាប/បិទស្លាក/គម្រោងការអំពីគម្រោងដៅសម្គាល់សត្វស្លាបទឹកទេសន្តរប្រវេសន៍។

១០.៤ មានការសម្របសម្រួលកម្រិតខ្ពស់ចំពោះការប្រគល់ឲ្យវិញនូវស្លាក និងរបាយការណ៍ឃើញស្លាកសម្គាល់ទាំងនោះ។

១០.៥ ការវិភាគនៃទិន្នន័យធ្វើទេសន្តរប្រវេសន៍សត្វស្លាបទឹក ត្រូវបញ្ចប់ និង
ធ្វើការទំនាក់ទំនងយ៉ាងទូលំទូលាយ

១០.៦ សកម្មភាពរួមបញ្ចូលសមាសភាពអភិវឌ្ឍសមត្ថភាពសមស្រប ។

**លទ្ធផល១១ : ចំណេះដឹងអំពីតួនាទីដែលមានសក្តានុពលនៃសត្វស្លាបទឹកទេសន្តរប្រវេសន៍ក្នុងការចម្លងរោគ ជាពិសេស គ្រុណផ្តាសាយបក្សី គឺត្រូវពង្រឹង**

១១.១ ក្រុមការងារផ្តាសាយបក្សីអាស៊ីប៉ាស៊ីហ្វិក ត្រូវគេបង្កើត និងគាំទ្រ ។

១១.២ គម្រោងត្រូវគេអនុវត្ត ដើម្បីបង្កើនការយល់ដឹងអំពីតួនាទីដែលមានសក្តានុពលនៃសត្វស្លាបទឹក
ទេសន្តរប្រវេសន៍ក្នុងការចម្លងជំងឺ ។

១១.៣ អាទិភាពត្រូវគេផ្តល់ឲ្យដល់គម្រោងដែលជាប់ទាក់ទិននឹងប្រភេទចម្លងជំងឺ ។

គោលបំណង៤ : **បង្កើនសមត្ថភាពគ្រប់គ្រងសត្វស្លាបទឹក និងទីជម្រក នៃអ្នកគ្រប់គ្រងធនធានធម្មជាតិ អ្នកធ្វើសេចក្តីសម្រេចទឹក និងអ្នកពាក់ព័ន្ធនៅមូលដ្ឋាន**

**លទ្ធផល១២: បង្កើនការយល់ដឹងនូវតម្រូវការសមត្ថភាពសំរាប់អ្នកពាក់ព័ន្ធ ដើម្បីគ្រប់គ្រងតំបន់សត្វស្លាបទឹក ដែលមានសារៈសំខាន់ជាអន្តរជាតិ**

១២.១: វាយតម្លៃតម្រូវការសមត្ថភាពត្រូវធ្វើឡើង ដើម្បីគ្រប់គ្រង និងតាមដានបណ្តាញតំបន់
ផ្លូវហោះហើរ ។

១២.២ វាយតម្លៃតម្រូវការបណ្តុះបណ្តាលត្រូវអនុវត្តចំពោះអ្នកពាក់ព័ន្ធសំខាន់ៗ សំរាប់ការគ្រប់គ្រង
និងការតាមដាននៃបណ្តាញតំបន់ផ្លូវហោះហើរ

១២.៣ អាទិភាពគឺត្រូវផ្តល់ឲ្យដល់ប្រទេសកំពុងអភិវឌ្ឍន៍ ។

**លទ្ធផល ១៣: អ្នកគ្រប់គ្រងធនធានធម្មជាតិ អ្នកធ្វើសេចក្តីសម្រេច និងអ្នកពាក់ព័ន្ធមូលដ្ឋាន នៅតំបន់ ដែលមានសារៈសំខាន់ជាអន្តរជាតិ មានជំនាញ និងគាំទ្រចំពោះការគ្រប់គ្រងទីជម្រកសត្វស្លាប ទឹកប្រកបដោយចីរភាព**

១៣.១ កម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព ត្រូវចាត់ជាសេចក្តីត្រូវការសំរាប់ការគ្រប់គ្រង
សត្វស្លាបទឹក ទីជម្រក ការអភិវឌ្ឍប្រកបដោយចីរភាព និងការទំនាក់ទំនង, ការអប់រំ
និងផ្សព្វផ្សាយជាសាធារណៈ។

១៣.២ បណ្តាញបង្កើនសមត្ថភាពជាតិត្រូវបង្កើត ដើម្បីសម្របសម្រួលការគ្រប់គ្រងទីជម្រក
និងសត្វស្លាបទឹកទេសន្តរប្រវេសន៍ដែលកំពុងបន្ត ។

១៣.៣ អាទិភាព គឺត្រូវផ្តល់ឲ្យប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានដៃគូរដ្ឋាភិបាលជាតិ
កំពុងយកចិត្តទុកដាក់ ចំពោះ៖

ក) ចំនួនតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិ នៅក្នុងប្រទេសនីមួយៗ

ខ) បានបញ្ចប់ការវាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាល សំរាប់អ្នកគ្រប់គ្រងតំបន់ដីសើម និងអ្នកធ្វើសេចក្តីសម្រេចចិត្ត។

គោលបំណង៥: អភិវឌ្ឍ ជាពិសេស ប្រភេទ និងទីជម្រកដែលជាអាទិភាព និងវិធីដ៏ទូលំទូលាយសម្រាប ផ្លូវហោះហើរ ដើម្បីពង្រឹងស្ថានភាពអភិរក្សនៃប្រភេទដែលជាអាទិភាព។

**លទ្ធផល១៤: វិធានការសហប្រតិបត្តិការផ្លូវហោះហើរទូលំទូលាយសម្រាបប្រភេទសត្វស្លាបទឹក និងទីជម្រកបាន និងកំពុងកែលំអរ ស្ថានភាពអភិរក្សនៃប្រភេទដែលជាអាទិភាព**

១៤.១ គម្រោងសម្របសម្រួលត្រូវបង្កើតឡើង សំរាប់ប្រភេទដែលជាអាទិភាពនៅទូទាំងដែនរស់នៅ របស់វា ។

១៤.២ អាទិភាពគឺផ្តល់ឲ្យប្រភេទដែលស្ថានភាពអភិរក្សមិនមែនគួរជាទីពេញចិត្ត ឬ សក្តានុពលដូចជា ប្រភេទសំខាន់(flagship) សម្រាប់ការគ្រប់គ្រងទីជម្រក និងកិច្ចសហការអន្តរជាតិ ។

១៤.៣ អាទិភាព គឺផ្តល់ឲ្យសម្រាប់គម្រោងដែលជាប់ទាក់ទងនឹងប្រទេសមួយចំនួន និងកំណត់ការ គម្រាមកំហែងសំខាន់ៗ ចំពោះកន្លែងរស់នៅរបស់សត្វស្លាបទឹកទេសន្តរប្រវេសន៍ ៕